# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ The Asian International Justice Initiative**

**ឆ្នាំទី១ លេខ ១៣** **សប្ដាហ៍ទី១៣ (២០-២២ កក្កដា ឆ្នាំ២០០៩)**


## "សវនាការអង្គសេចក្ដីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព : សាក្សី **ប្រាក់ ខន** ( អតីតអ្នកសួរចម្លើយនៅមន្ទីរ ស-២១)*

## ១. សេចក្ដីសង្ខេប

*" នៅពេលខ្ញុំឃើញគាត់ ខ្ញុំនឹកឃើញដល់ពេលវេលាដែលយើងធ្វើការជាមួយគ្នា ។ ខ្ញុំខ្លាចគាត់ ខ្ញុំមិនហ៊ានមើលមុខគាត់ទេ សូម្បីតែឥឡូវ [1] "*

នាសប្ដាហ៍នេះ សវនាការបានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃ ដោយស្ដាប់សក្ខីកម្មរបស់អតីតបុគ្គលិកមន្ទីរ ស-២១ ចំនួន ៣រូប រួមមាន លោក **ហ៊ឹម ហ៊ុយ** ដែលបានផ្ដល់សក្ខីកម្មតាំងពីសប្ដាហ៍មុន លោក **ប្រាក់ ខន** និងលោក **គក ស្រស់** ដែលត្រូវបានចាប់ផ្ដើមកិច្ចនីតិវិធីតែបន្តិច ប៉ុន្តែត្រូវអាក់ខាន ដូច្នេះសក្ខីកម្មរបស់លោក **គក ស្រស់** ត្រូវលើកទៅធ្វើនៅថ្ងៃច័ន្ទ ទី២៧ ខែកក្កដា ឆ្នាំ ២០០៩ វិញ ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្ដីសង្ខេបសក្ខីកម្ម :

ខាងក្រោមនេះ គឺជាសេចក្ដីសង្ខេបសក្ខីកម្មផ្ដល់ដោយសាក្សីសប្ដាហ៍នេះ :

### លោក ហ៊ឹម ហ៊ុយ

នៅថ្ងៃច័ន្ទ លោក **ហ៊ឹម ហ៊ុយ** អាយុ ៥៤ឆ្នាំ ដែលជាអតីតអ្នកសួរចម្លើយនៅមន្ទីរ ស-២១ បានបន្តផ្ដល់សក្ខីកម្មខ្លួនទៀត

[1] សក្ខីកម្មសាក្សី **ហ៊ឹម ហ៊ុយ** និយាយសំដៅជនជាប់ចោទ កាំង ហ្គិចអ៊ាវ ហៅ ឌុច ។

នៅចំពោះមុខអង្គជំនុំជម្រះ ។ គាត់បានឱ្យដឹងថា គាត់បានចាប់ផ្តើមធ្វើជាឆ្មាំយាមគុកនៅឆ្នាំ ១៩៧៦ ហើយក្រោយមកបានឡើងតំណែងជាអ្នកសួរចម្លើយនៅឆ្នាំ ១៩៧៧ ។ លោក **ហ៊ឹម ហ៊ុយ** មិនបានអនុវត្តសិទ្ធិនៅស្ងៀមជាញឹកញាប់ដូចលោក **ម៉ម ណៃ** នោះទេ លើកលែងតែសក្ខីភាពទាក់ទងនឹងសកម្មភាពធ្វើទារុណកម្ម ។ ខាងក្រោមនេះជាសក្ខីកម្មរបស់គាត់ :

***ការបែកបាក់ទំនាក់ទំនងរវាងឌុច និង ហ៊ីរ*** : នៅថ្ងៃច័ន្ទ លោក **ហ៊ឹម ហ៊ុយ** បានរៀបរាប់ពីទំនាស់រវាង **ហ៊ីរ** និង **ឌុច** លើការប្រកាន់បក្សពួកនិយម ។ **ឌុច** មានការអនុគ្រោះ និងយោគយល់ចំពោះបុគ្គលិកមកពីតំបន់បស្ចឹម ចំណែក **ហ៊ីរ** ជាអតីតបុគ្គលិកមកពីកងពល ៧០៣ ។ បញ្ហានេះ បានធ្វើឱ្យបុគ្គលិកមន្ទីរ ស-២១ មកពីកងពល ៧០៣ ភាគច្រើនត្រូវបានកំទេច ដែលកំណត់មុខសញ្ញាដោយ **ឌុច** ក្នុងគោលបំណងចាប់ខ្សែរយៈដែលមានការពាក់ព័ន្ធ ។ តំណាងសហព្រះរាជអាជ្ញា ហាក់យល់ដឹងពីបញ្ហានេះបន្ទាប់ពេលវេលាកំណត់ត្រូវអស់ ហើយអង្គជំនុំជម្រះបានបដិសេធមិនផ្តល់ពេលបន្ថែមឱ្យទៅសហព្រះរាជអាជ្ញាតាំងសំណួរបញ្ចប់ទេ ។ (សូមមើល ***បញ្ហាច្បាប់ និង នីតិវិធី*** នៅក្នុងរបាយការណ៍នេះ) ។

***លក្ខខណ្ឌនៃការឃុំខ្លួន*** : លោក **ហ៊ឹម ហ៊ុយ** បានផ្តល់ព័ត៌មានលម្អិតអំពីការប្រព្រឹត្តចំពោះអ្នកទោស ។ លោកបញ្ជាក់ថា ជាគោលការណ៍ អ្នកទោសអនុញ្ញាតិឱ្យស្លៀកតែខោខ្លីទេ នៅក្នុងគោលបំណងបញ្ចៀសការធ្វើអត្តឃាត ។ ចំពោះអ្នកទោសដែលជាអតីតបុគ្គលិកមន្ទីរ ស-២១ ត្រូវបានបណ្តើរចេញយកទៅសួរចម្លើយ ពួកគេត្រូវបានរុំភួយ ដើម្បីការពារមិនឱ្យបុគ្គលិកមន្ទីរ ស-២១ ផ្សេងទៀតស្គាល់ ។

***ការចូលរួមសួរចម្លើយ និងធ្វើទារុណកម្ម*** : នៅថ្ងៃច័ន្ទ មេធាវីដើមបណ្តឹងក្រុម ១ និងក្រុម ២ បានឱ្យលោក **ហ៊ឹម ហ៊ុយ** បញ្ជាក់ពីភាពពិតនៃសេចក្តីថ្លែងផ្តល់ទៅសហចៅក្រមស៊ើបអង្កេត កំឡុងពេលសម្តែងឡើងវិញនៅមន្ទីរ ស-២១ កាលពីថ្ងៃទី ២១ កុម្ភៈ ២០០៨ ។ នៅពេលនេះ លោក **ហ៊ុយ** ទទួលស្គាល់តួនាទីសំដែងធ្វើទារុណកម្មលើអ្នកទោស ។ លោក **ហ៊ុយ** ប្រកាន់ខ្ជាប់ការបដិសេធថា គាត់មិនធ្លាប់ធ្វើទារុណកម្មអ្នកទោសណាម្នាក់ទេ ។ លោក **ហ៊ុយ** ក៏បដិសេធជាក់លាក់ថា គាត់មិនបានធ្វើទារុណកម្មលោក **ប៊ូ ម៉េង** (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២) នោះទេ ។ គាត់បានអះអាងថា ក្នុងនាមជាឆ្មាំយាមគុក គាត់មិនមានសិទ្ធិប្រព្រឹត្តអំពើហិង្សាដូច្នោះទេ ក៏ប៉ុន្តែ គាត់ទទួលស្គាល់ថា មានហេតុការណ៍មួយកើតឡើង នៅពេលគាត់ឱ្យលោក **ប៊ូ ម៉េង** លើកបីគាត់ដើម្បីបង្ហាញពីភាពខ្លាំង តែគ្រាន់តែជាការលែងសើចប៉ុណ្ណោះ ។ មេធាវីការពារក្តីអន្តរជាតិលោក **Francois Roux** គូសបញ្ជាក់ ថា ខណៈដែលលោក **ហ៊ុយ** ចាត់ទុករឿង នោះជាការលែងសើច ប៉ុន្តែជនរងគ្រោះចាត់ទុកជារឿងពិត ។

***វចនាសម្ព័ន្ធមន្ទីរ ស-២១*** : តាមការអះអាងរបស់លោក **ហ៊ុយ** ការតែងតាំងឋានៈនៅមន្ទីរ ស-២១ ធ្វើឡើងដោយផ្ទាល់មាត់មិនមានជាលាយលក្ខអក្សរទេ ។ គាត់ត្រូវតំឡើងឋានៈជាប្រធានកងរយ បន្ទាប់ពីមិត្តរួមការងារជាច្រើននាក់បាន *"បាត់ខ្លួន"* ។ លោកជឿជាក់ថា **ឌុច** មិនទទួលបញ្ជាអ្នកណាទេនៅមន្ទីរ ស-២១ គាត់ជាអ្នកមានតួនាទី និងអំណាចធំជាងគេនៅក្នុងមន្ទីរសន្តិសុខ ។ ស្របនឹងការលើកឡើងរបស់ជនជាប់ចោទ ស្តីពីមនោគមវិជ្ជាខ្មែរក្រហម លោកបានបរិយាយថា បុគ្គលិកមន្ទីរ ស-២១ ត្រូវជឿជាក់លើ *"អង្គការ"* គ្រប់សកម្មភាព ។ ចំពោះអ្នកមិនគោរព និងអនុវត្តតាមត្រូវចាត់ទុកថាជាខ្មាំង ត្រូវចាប់ និងឃុំខ្លួន ។

ការបញ្ចូល *"មនោគមវិជ្ជា"* បានលាតសន្ធឹងដល់ការងារឆ្មាំគុក ព្រោះជាអ្នកទទួលខុសត្រូវយាមកាមអ្នកទោសឱ្យបានមុតមាំ កំឡុងអ្នកសួរចម្លើយ ទាញយកសេចក្ដីសារភាព ។ ការខកខានមិនអនុវត្តបទបញ្ជា មានន័យថា ធ្វើឱ្យបរាជ័យតម្រូវការបក្ស ។

***ដំណើរការទទួលយកអ្នកទោស*** : អ្នកទោសទាំងអស់ត្រូវចាត់ថ្នាក់ ឬប្រភេទ ដោយផ្អែកលើឯកសារទទួលបានមុន ដូចជា អ្នកទោសត្រូវជ្រើសរើសដាក់មន្ទីរអប់រំកែប្រែព្រៃស និងអ្នកទោសត្រូវដាក់ឃុំនៅមន្ទីរ ស-២១ ។ លោក ហ៊ឹម ហ៊ុយ បានអះអាងថា **ឌុច** ជាមនុស្សមានអំណាចជាងគេនៅមន្ទីរសន្តិសុខ ដូច្នេះរាល់សេចក្ដីសម្រេចទាក់ទងនឹងការចាត់តាំងអ្នកទោសទៅទីកន្លែងនានា គឺជាតួនាទី និងការទទួលខុសត្រូវរបស់គាត់ ។

***អ្នកទោសជនជាតិវៀតណាម*** : ផ្អែកលើការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាជាតិ លោក **ហ៊ឹម ហ៊ុយ** បានរៀបរាប់ថា ចម្លើយសារភាពអ្នកទោសជនជាតិវៀតណាម ត្រូវថតខ្សែអាត់ និងចាក់ផ្សាយតាមវិទ្យុ ។ គាត់រំលឹករឿងកើតឡើងមួយ នៅពេលអ្នកទោសវៀតណាមតម្រូវឱ្យដើរជាក្បួនតាមផ្លូវ ស្ថិតក្នុងសំលៀកបំពាក់ទាហ៊ាន ហើយត្រូវបានថតរូប ។ ករណីនេះ ស៊ីសង្វាក់ ទៅនឹងសក្ខីកម្មមុនរបស់ជនជាប់ចោទដែលថា ឯកសារពាក់ព័ន្ធអ្នកទោសជនជាតិវៀតណាម និងចម្លើយសារភាពរបស់ពួកគេត្រូវប្រើប្រាស់ក្នុងគោលបំណងឃោសនាក្នុងរបបខ្មែរក្រហម ។

***អ្នកទោសកុមារ*** : នៅពេលសួរអំពីកុមារនៅឯមន្ទីរ ស-២១ លោក **ហ៊ឹម ហ៊ុយ** អះអាងថា អ្នកទោសកុមារត្រូវចាប់ចេញពីម្ដាយ ហើយ **ប៉េង** ជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់កុមារ ។ គាត់ក៏បានបញ្ជាក់ថា កុមារត្រូវយកចេញមុនសម្លាប់ឪពុកម្ដាយរបស់ពួកគេ ។ គាត់បន្ថែមថា កុមារប្រមាណជា ១០០នាក់ ត្រូវបានសម្លាប់នៅមន្ទីរ ស-២១ ។

***ការរំលោភ :*** លោក **ហ៊ឹម ហ៊ុយ** ចងចាំថា មានករណីរំលោភមួយបានកើតឡើង ដោយអ្នកយាមប្រព្រឹត្តទៅលើអ្នកទោសស្ត្រី ។ ក្រោយមក គាត់មិនដឹងថា មានរឿងអ្វីកើតឡើងចំពោះជនរងគ្រោះ និងអ្នកប្រព្រឹត្តនោះទេ ។

***ការបណ្ដុះបណ្ដាល :*** សាក្សី **ហ៊ឹម ហ៊ុយ** បានបញ្ជាក់ពីការលើកឡើងមុនរបស់ជនជាប់ចោទថា វគ្គវណ្ដុះបណ្ដាលសម្រាប់អង្គភាពផ្សេងៗត្រូវបានធ្វើឡើងនៅអាគារជិតផ្ទះ **ឌុច** ។ វគ្គបណ្ដុះបណ្ដាលនោះត្រូវរៀបចំជារៀងរាល់ ២សប្ដាហ៍ម្ដង សម្រាប់តែអង្គភាពសួរចម្លើយប៉ុណ្ណោះ ។

***ការដោះលែង និងការជៀសវាងកុំឱ្យចាប់ខ្លួន :*** កាលពីសប្ដាហ៍មុន លោក **ហ៊ឹម ហ៊ុយ** លើកឡើងថា គាត់ជឿថាមានការដោះលែងក្រុមអ្នកទោសជនជាតិថៃនៅមន្ទីរ ស-២១ នៅពេលនោះអ្នកទោសត្រូវបញ្ជូនចេញក្រៅដោយសម្លៀកបំពាក់សមរម្យ មិនចងមុខ និងដាក់ខ្នោះទេ ក៏ប៉ុន្តែ នៅថ្ងៃចន្ទ ជនជាប់ចោទបញ្ជាក់ពីបញ្ជីកំទេចចងក្រងដោយការិយាល័យសហព្រះរាជអាជ្ញា ដោយថា ក្រុមអ្នកទោសជនជាតិថៃត្រូវបានកំទេចទាំងអស់ ។

***ការពារកុំឱ្យគេចាប់ខ្លួន :*** ដូចករណីលោក **ម៉ម ណៃ** លោក **ហ៊ឹម ហ៊ុយ** ហាក់ចង់បង្ហាញថា នៅពេលគ្មាននរណាម្នាក់អាចត្រូវដោះលែងអ្នកទោសនៅមន្ទីរ ស-២១ វាអាចមានលទ្ធភាពក្នុងការធានាបានចំពោះកម្មាភិបាលផ្សេងទៀតពីការចាប់ខ្លួន ។ គាត់រំលឹក

ថា ព្រឹត្តការណ៍ អ្នកក្រោមបង្គាប់ម្នាក់ត្រូវបានបញ្ជូនទៅគុកព្រៃស ដោយការធានារបស់គាត់ចំពោះមុខ **ហ៊ីរ** ។

## សាក្សី ប្រាក់ ខន

លោក **ប្រាក់ ខន** អាយុ ៥៨ឆ្នាំ បានអះអាងថា គាត់ជាអតីតអ្នកសួរចម្លើយនៅមន្ទីរ ស-២១ ។ គាត់ចូលរួមបដិវត្តន៍នៅឆ្នាំ១៩៧២ ការងារដំបូងនៅអង្គភាពកសិកម្មសាលាលេខ៦ ស្រុកបាទី ខេត្តតាកែវ ។ បន្ទាប់មក គាត់ត្រូវផ្ទេរទៅធ្វើការនៅអង្គភាពយោធាជាសមាជិកអង្គភាពពិសេសនៅកងពល ១២ ក្រោយមកនៅកងពល ៧០៣ ។ បន្ទាប់ពីចូលរួមរំដោះភ្នំពេញ លោក **ប្រាក់ ខន** ត្រូវបានបញ្ជូនទៅធ្វើស្រែនៅព្រៃស ។ ក្រោយមក គាត់រួមនឹងសមាជិកកងអនុសេនាតូច ១៣៨ ត្រូវផ្លាស់មកធ្វើអ្នកយាមនៅមន្ទីរ ស-២១ ដោយយាមបរិវេណខាងក្រៅមន្ទីរ ។ ចុងឆ្នាំ ១៩៧៦ គាត់ត្រូវតែងតាំងឱ្យធ្វើជាអ្នកសួរចម្លើយ ។

***ការសួរចម្លើយ និងការធ្វើទារុណកម្ម :*** លោក **ប្រាក់ ខន** ធ្វើការបញ្ជាក់ពីការរៀបរាប់របស់ **ឌុច** ដែលថា មានក្រុមសួរចម្លើយ ៣ក្រុម នៅមន្ទីរ ស-២១ គឺក្រុមត្រជាក់ ក្រុមក្តៅ និងក្រុមអង្គាម ។ *ក្រុមត្រជាក់* គឺប្រើ *"នយោបាយ"* ដើម្បីសួរយកចម្លើយ *ក្រុមអង្គាម* ប្រើវិធីសួរច្រំដែលៗរហូតទទួលបានចម្លើយសារភាព ក្រុមនេះអាចប្រើអំពើហិង្សាបាន ចំណែក *ក្រុមក្តៅ* គឺប្រើហឹង្សាគ្រប់ពេលសួរចម្លើយ ។ តាមសម្តីលោក **ប្រាក់ ខន** អ្នកសួរចម្លើយនៅមន្ទីរ ស-២១ អនុវត្តនតាមវិន័យដ៏តឹងរឹងរបស់ **ឌុច** ដោយអ្នកទោសមិនអាចត្រូវបានវាយដល់ស្លាប់នោះទេ។ លោក **ប្រាក់ ខន** បញ្ជាក់ថា គាត់ស្ថិតនៅក្នុងក្រុមអង្គាម ។

ចំពោះសេចក្តីថ្លែងមុនរបស់ជនជាប់ចោទ សាក្សីពន្យល់ថា ជាទូទៅ អ្នកសួរចម្លើយអនុវត្តការងារតែម្នាក់ឯង ខណៈ **ឌុច** យូៗម្តងដើរត្រួតពិនិត្យ និងចូលសួរចម្លើយអ្នកទោសពីរទៅបីសំណួរ ។ ចំពោះការសួរចម្លើយអ្នកទោសស្ត្រី បន្ទប់សួរចម្លើយត្រូវចំហរទ្វារ និងបង្អួច ដើម្បីចៀសវាងកំហុសសីលធម៌ ។

***សេវាពេទ្យនៅមន្ទីរ ស-២១ :*** យោងតាមលោក **ប្រាក់ ខន** អង្គភាពពេទ្យមានសមាជិក ៤-៥ រូប រួមមានទាំងស្ត្រីផងដែរ ។ ការលើកឡើងរបស់លោក **ប្រាក់ ខន** គឺជាសក្ខីកម្មដំបូងដែលគាំទ្រសក្ខីកម្មរបស់លោកស្រី **ណាំ ម៉ុន** ដែលអះអាងថា ជាពេទ្យនៅមន្ទីរ ស-២១ ។ ជាងនេះទៀត លោក **ប្រាក់ ខន** បញ្ជាក់ថា លោកស្រី **ណាំ ម៉ុន** ជាពេទ្យព្យាបាលគាត់នៅមន្ទីរ ស-២១ ។ ទោះបីជាយ៉ាងណា គាត់ទទួលស្គាល់ថា ការរៀបរាប់នេះដោយហេតុបន្ទាប់បានឃើញលោកស្រី **ណាំ ម៉ុន** ផ្តល់សក្ខីកម្មនៅតុលាការនេះ តាមទូរទស្សន៍ ។ បញ្ហានេះកាន់តែស្មុគ្រស្មាញ នៅថ្ងៃពុធ ដែលលោក **ប្រាក់ ខន** លើកឡើងថា ពេទ្យស្រីឈ្មោះ **ចុន** មកពីប្រទេសចិនបានព្យាបាលគាត់ដោយប្រើម្ជុលវិទ្យាសាស្ត្រ ។

***ការបណ្តុះបណ្តាលអ្នកសួរចម្លើយ :*** សាក្សីលោក **ហ៊ឹម ហ៊ុយ** និង **ប្រាក់ ខន** បញ្ជាក់បន្ថែមលើសក្ខីកម្មជនជាប់ចោទ ដោយថ្លែងថា វគ្គបណ្តុះបណ្តាលត្រូវរៀបចំឡើងជាញឹកញាប់នៅមន្ទីរ ស-២១ ពោលគឺ រៀងរាល់ពីរសប្តាហ៍ ឬរាល់ខែ ឬពីរខែ ។ វគ្គសិក្សានេះរៀបចំនៅកន្លែងមួយហៅថា ***សាលានយោបាយ*** ហើយ **ឌុច** គឺជាគ្រូបង្រៀន ។ សាក្សីលើកឡើងថា វគ្គបណ្តុះបណ្តាលរៀបចំសម្រាប់ តែអង្គភាពសួរចម្លើយ ហើយពេលខ្លះរៀបចំសម្រាប់អង្គភាពមន្ទីរ ស-២១ ទាំងមូល ។ វគ្គសិក្សានេះ **ឌុច** បង្រៀន

កម្មាភិបាលពីបច្ចេកទេសសួរចម្លើយ និងពន្យល់អំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ។ ទោះបីជាសក្ខីកម្មពេលខ្លះលោក **ប្រាក់ ខន** លើកឡើងថា មានតែក្រុមសួរចម្លើយចូលរៀនវគ្គបណ្តុះបណ្តាលនេះក៏ដោយ ។

***ការបូមឈាម :*** លោក **ប្រាក់ ខន** រៀបរាប់ពីវិធីបូមឈាម នៅពេលគាត់បណ្តើរអ្នកទោសទៅបន្ទប់សួរចម្លើយ គាត់បានឃើញការបូមឈាមអ្នកទោសដោយផ្ទៃដៃវេជ្ជ ។ សាក្សីបញ្ជាក់ថា បានដើរកាត់បន្ទប់ពេទ្យ និងឃើញអ្នកទោសដេកលើគ្រែជើងជាប់ខ្នោះដោយមានម្ជុលដោតជាប់សរសៃបង្ហូរឈាមបញ្ចូលក្នុងប្លោកឈាម ។ សាក្សីជឿថា ឈាមទាំងនេះត្រូវយកទៅព្យាបាលទាហ៊ានខ្មែរក្រហម ដែលរងរបួសក្នុងជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម ចន្លោះ ឆ្នាំ១៩៧៧ និង ឆ្នាំ១៩៧៨ ។ លោក **ប្រាក់ ខន** សន្និដ្ឋានថា អ្នកទោសប្រមាណជា ១០-២០ នាក់ ត្រូវបូមឈាមជារៀងរាល់ថ្ងៃ ។ អ្នកទោសម្នាក់ៗត្រូវបូមឈាមចេញយ៉ាងតិច ៤-៥ ប្លោក បន្ទាប់មកពួកគេនៅសល់តែដង្ហើមចង្រិត និងទុកចោលឱ្យស្លាប់ ។ លោក **ប្រាក់ ខន** អះអាងថា ឈាមទាំងនោះត្រូវបញ្ជូនទៅមន្ទីរពេទ្យព្រះកេតុមាលា មន្ទីរពេទ្យព្រះមុន្នីវង្ស និងមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត ។ សាក្សីបន្ថែមទៀតថា ចំពោះសាកសពស្លាប់ ដោយការបូមឈាមត្រូវបានកប់នៅបរិវេណជុំវិញមន្ទីរ ស-២១ និងដឹកចេញក្រៅតាមរថយន្ត នៅពេលមានសាកសពច្រើន ។

***ការរំលោភផ្លូវភេទ :*** នៅពេលចៅក្រម Lavergne សួរដេញដោលពីករណីរំលោភផ្លូវភេទកើតមាននៅមន្ទីរ ស-២១ លោក **ប្រាក់ ខន** រៀបរាប់ថា ករណីរំលោភមួយលើអ្នកទោសស្ត្រីម្នាក់ប្រព្រឹត្តដោយអ្នកយាមឈ្មោះ **ទូច** ក្នុងពេលសួរចម្លើយ ។ សាក្សីបន្តថា ក្រោយហេតុការណ៍នោះ អ្នកប្រព្រឹត្តត្រូវចាប់ខ្លួនដោយ **ម៉ម ណៃ** ហៅ **ចាន់** ពីបទខុសសីលធម៌ ។ សាក្សីបន្ថែមថា ហេតុការណ៍នេះធ្វើឱ្យមានវិន័យថ្មីកើតឡើង លើការសួរចម្លើយអ្នកទោសស្ត្រី ។ វិន័យថ្មីចែងថា នៅពេលសួរអ្នកទោសស្ត្រី *"បន្ទប់សួរចម្លើយត្រូវចំហរទ្វារ បើកបង្អួច"* ដើម្បីចៀសវាងកំហុសសីលធម៌ ។

***អ្នកទោសកុមារនៅមន្ទីរ ស-២១ :*** សក្ខីកម្មលោក **ប្រាក់ ខន** បានលាតត្រដាងពីឧបទ្ទវហេតុទម្លាក់ក្មេងពីអាគារជាន់លើដោយកងសន្តិសុខមន្ទីរ ស-២១ ។ លោក **ប្រាក់ ខន** ផ្តល់សក្ខីកម្មថា **ដែក ប៊ូ** បានទាញក្មេងពីម្តាយជនជាតិវៀតណាម ហើយបោះទម្លាក់មកក្រោម ដែលជាកន្លែងសាក្សីឈរយាម បន្ទាប់មក **ប៊ូ** បញ្ជាឱ្យគាត់យកសពក្មេងនោះទៅកប់នៅបរិវេណមន្ទីរ ស-២១ ដែលគាត់បានឃើញហេតុការណ៍នេះតែម្តងគត់ ។ **ឌុច** បដិសេធហេតុការណ៍នោះ ដោយអះអាងថា អាគារកំពស់បីជាន់ពុំមានទេនៅមន្ទីរ ស-២១ ។

***ការបែកបាក់ទំនាក់ទំនងរវាង ឌុច និង ហ៊ីរ :*** លោក **ប្រាក់ ខន** បានបញ្ជាក់ថា ដំណាក់កាលចុងក្រោយរបបខ្មែរក្រហម បុគ្គលិកមន្ទីរ ស-២១ ប្រមាណ ៣០០នាក់ មកពីកងពល ៧០៣ ត្រូវបោសសំអាតនៅសល់តែ ៥-៦ នាក់ ប៉ុណ្ណោះ ។ លោក **ប្រាក់ ខន** អះអាងថា សមាជិកកងពល ៧០៣ គឺជាក្រុមគោលដៅ និងមុខសញ្ញា ដែល **ឌុច** ត្រូវកំទេច ព្រោះគាត់មិនចង់ឱ្យកងពលនេះមានអំណាចទេ ព្រោះ **ឌុច** បារម្ភខ្លាចបាត់បង់តំណែងជាប្រធាន ។

## សាក្សី គក ស្រស់

លោក **គក ស្រស់** ជាសាក្សីកោះហៅចូលផ្តល់សក្ខីកម្មនៅរសៀលថ្ងៃពុធ ប៉ុន្តែសក្ខីកម្មចាប់ផ្តើមបន្តិច អង្គជំនុំជម្រះសម្រេចផ្អាកលើកទៅសប្តាហ៍ក្រោយ (ថ្ងៃច័ន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០០៩) ដោយសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងក្រុម២ លោកស្រី **Silke Studzinsky** បានដាក់ការសន្និដ្ឋានថ្មីរបស់ខ្លួន ។ កិច្ចដំណើរការនីតិវិធីហាក់អូសបន្លាយយូរជាងកាលវិភាគបំរុងទុក ។

## ២. បញ្ហា/ក្តីកង្វល់លើកឡើងពេលដំណើរការសវនាការ

***សវនាការអសាធារណៈលើការដាក់ការសន្និដ្ឋានស្តីពី "ការមិនឆ្លើយដាក់ពិរុទ្ធភាពខ្លួនឯង" :*** សហព្រះរាជអាជ្ញាត្រូវបានស្តីបន្ទោស ដោយធ្វើឱ្យបែកខ្ចាយព័ត៌មានដល់សាធារណៈជន ។ គោលបំណងសវនាការអសាធារណៈ ដើម្បីពិភាក្សាអំពីសិទ្ធិសាក្សីប្រឆាំងនឹងការមិនឆ្លើយដាក់ពិរុទ្ធភាពខ្លួនឯង នៅថ្ងៃច័ន្ទ បន្ទាប់ពីសហព្រះរាជអាជ្ញាស្នើសុំ ដោយអនុលោមតាមវិធាន ២៨(៨) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះចាត់ទុកថា *"មិនសមស្រប"* ទេនៅសប្តាហ៍នេះ ។ អង្គជំនុំជម្រះប្រកាសថា មូលហេតុសវនាការអសាធារណៈ មិនស្ថិតក្រោមវិធាន២៨(៨)ទេ ។ នេះជាលទ្ធផលល្អ គួរកោតសរសើរក្នុងកិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះ ដើម្បីធានាតម្លាភាពកិច្ចដំណើរការនីតិវិធី ។ គួរឱ្យកត់សម្គាល់ អង្គជំនុំជម្រះបង្គាប់មេធាវីការពារក្តីមិនឱ្យដាស់តឿនសាក្សី ពីសិទ្ធិនៅស្ងៀមមិននិយាយ ក្នុងពេលសវនាការ ។

***សាក្សីលាតត្រដាងពីសក្ខីកម្មសាក្សីមុន :*** នៅថ្ងៃអង្គារ លោក **ប្រាក់ ខន** បានសារភាពថា គាត់អាចចំណាំលោកស្រី **ណាំ ម៉ុន** ជាពេទ្យនៅ មន្ទីរ ស-២១ តាមទូរទស្សន៍ នៅពេលលោកស្រីបានមកផ្តល់សក្ខីកម្ម ។ បើទោះបីជា អង្គជំនុំជម្រះបានសម្រេចមិនឱ្យសាក្សីមានវត្តមានក្នុងសវនាការមុនពេលផ្តល់សក្ខីកម្ម ក៏ប៉ុន្តែពុំបានចាត់វិធានការណ៍មិនឱ្យស្តាប់សក្ខីកម្មតាមទូរទស្សន៍ដែរ ។ ការស្តាប់ឮសក្ខីកម្មមុនៗ ជាហេតុផលធ្វើឱ្យសាក្សីអាចបន្ថែមបន្ថយសក្ខីកម្មរបស់ខ្លួន ឬផ្តល់ការលំបាកនៃភាពជឿជាក់លើភស្តុតាងដែលមានប្រយោជន៍ ។ ជាការពិត បរិបទរបស់អ.វ.ត.ក ធានាឱ្យដំណើរការសវនាការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ប៉ុន្តែតើត្រូវចាត់វិធានការណ៍បែបណា ចំពោះសាក្សីមិនទាន់ផ្តល់សក្ខីកម្ម *ប្រសិនបើពួកគេទទួលបានព័ត៌មានទាំងនេះ* ។

## ៣. ការចូលរួមរបស់ជនរងគ្រោះ និងសាក្សី និងការការពារជនរងគ្រោះ និងការគាំទ្រ

***វត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណី :*** នាសប្តាហ៍នេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១ រូប មានវត្តមានក្នុងបន្ទប់សវនាការ ។ ក្រុមអ្នកឃ្លាំមើលតុលាការក៏សង្កេតឃើញមានវត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត នៅក្នុងបន្ទប់សាធារណៈផងដែរ នៅថ្ងៃច័ន្ទ។

***ការសាកសួររបស់មេធាវីជំនួសកូនក្តី :*** នៅថ្ងៃច័ន្ទនេះ នៅពេលសួរដេញដោលសាក្សី **ហ៊ឹម ហ៊ុយ** លោកស្រីមេធាវី **Silke Studzinsky** ទទួលបានឱកាសទាំងអស់សួរដេញដោលសាក្សី លើអង្គហេតុលោក **ប៊ូ ម៉េង** និងប្រពន្ធគាត់នៅមន្ទីរ ស-២១ ។ លោកស្រីបង្ហាញថា ការសួរដេញដោលនេះ គឺឆ្លើយតបនឹងក្តីកង្វល់របស់ជនរងគ្រោះ ។ របៀបនៃការតាំងសំណួរក៏ខុសពីមេធាវី

ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗដែរ ដែលដេញដោលលើភស្តុតាងពាក់ព័ន្ធនឹងការចោទប្រកាន់ជនជាប់ចោទ ។ ទោះបីយ៉ាងណា អង្គជំនុំជម្រះនៅតែអនុញ្ញាតឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតាំងសំណួររបៀបនោះ ។

***សំណួរច្រំដែល :*** **បើ**ទោះបីជា ភាគីប្រកាន់ខ្ជាប់ពេលវេលាកំណត់ដោយអង្គជំនុំជម្រះក៏ដោយ ក៏នៅតែមានការតាំងសំណួរច្រំដែល ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ នៅថ្ងៃច័ន្ទ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោក **ហុង គីមសួន** បានតាំងសំណួរច្រំដែលជាច្រើន ដែលអង្គជំនុំជម្រះ និងភាគីផ្សេងបានសាកសួរសាក្សី **ហ៊ីម ហ៊ុយ** រួចហើយ ។ មេធាវីការពារក្តីអន្តរជាតិលោក **Roux** បានបង្អាក់សំណួរទាំងនោះ ហើយប្រធានអង្គជំនុំជម្រះបានណែនាំសាក្សីជាបន្តបន្ទាប់មិនឱ្យឆ្លើយតប ។

***ការអនុវត្តន៍សិទ្ធិមិនឆ្លើយដាក់ពិរុទ្ធភាពខ្លួនឯង :*** យោងតាមបញ្ហាលើកឡើងជាបន្តបន្ទាប់ លើសិទ្ធិមិនឆ្លើយដាក់ពិរុទ្ធភាពខ្លួនឯងដោយសាក្សី **ម៉ម ណៃ** អង្គជំនុំជម្រះហាក់មានការប្រុងប្រយ័ត្នចំពោះបញ្ហានេះ នាសប្តាហ៍នេះ ។ អង្គជំនុំជម្រះ តែងតែប្រាប់សាក្សីឱ្យដឹងជាមុន អំពីភាពប្រឈមមុខនឹងការឆ្លើយដាក់បន្ទុកខ្លួនឯង និងប្រាប់ពីការអនុវត្តន៍សិទ្ធិនៅស្ងៀមមិនឆ្លើយ ។ម្យ៉ាងទៀត អង្គជំនុំជម្រះក៏បានណែនាំសាក្សីអំពីករណីកិច្ចត្រូវបំពេញ ក្នុងនាមជាសាក្សី គឺឆ្លើយការណ៍ណាដែលពិត ។

***តើជនជាប់ចោទសម្លុតបំភ័យសាក្សី? ក្តីកង្វល់អំពីសិទ្ធិរបស់សាក្សីត្រូវបានរំលោភ :*** នៅថ្ងៃពុធ កំឡុងពេលសួរដេញដោលសាក្សី **ប្រាក់ ខន** លោកស្រីមេធាវី **Martine Jacquin** បានសុំការអនុញ្ញាតពីអង្គជំនុំជម្រះ សួរផ្ទាល់ទៅជនជាប់ចោទ ចំពោះសក្ខីកម្មលោក **ប្រាក់ ខន** ។ ឆ្លៀតឱកាសនោះ **ឌុច** ជំទាស់សក្ខីកម្មដែលអះអាងដោយសាក្សី **ប្រាក់ ខន** និងបដិសេធដោយផ្ទែកៗ ចំពោះសក្ខីកម្មទាំងនោះ និងថ្លែងទៅកាន់សាក្សីដោយផ្ទាល់ថា រាល់ការលើកឡើងរបស់សាក្សី គឺគ្មានភស្តុតាងបញ្ជាក់ឡើយ ។

តាមហេតុការណ៍នេះ សហព្រះរាជអាជ្ញាអន្តរជាតិលោក **William Smith** បានដាក់សេចក្តីសន្និដ្ឋានថា ជនជាប់ចោទគួរត្រូវចោទសួរ និងផ្តល់ឱកាសធ្វើសេចក្តីសង្កេត បន្ទាប់ពីសាក្សីបញ្ចប់សក្ខីកម្មខ្លួន *ឧទា :* បន្ទាប់ពីការសួរដេញដោល ដោយមេធាវីការពារក្តី ។ យោងតាមវិធាន ២៩ នៃវិធានផ្ទៃក្នុង លើកឡើងថា ការគាំពារសាក្សី អង្គជំនុំជម្រះត្រូវ *"ធានាឱ្យមានបរិយាកាសល្អដល់សាក្សីក្នុងការផ្តល់សក្ខីកម្មរបស់ខ្លួន"* ។ លោក **Smith** បានដាក់ការសន្និដ្ឋានថា យោបល់របស់ជនជាប់ចោទ និងការសង្កេតនានា គួរធ្វើក្រោយការបញ្ចប់សក្ខីកម្មរបស់សាក្សី ។ ការតទល់មុនការបញ្ចប់សក្ខីកម្មសាក្សី ហាក់រំលោភសិទ្ធិគាំពារដោយច្បាប់ ជាពិសេស អង្គហេតុថា **ឌុច** ខ្លាចក្រែងបុគ្គលិកមន្ទីរ ស-២១ ជួនកាលថ្លែងតវ៉ាថា សាក្សីទាំងនោះ មានឥរិយាបថមិនស្តាប់បង្គាប់ ។ អង្គជំនុំជម្រះលើកថា ការសម្រេចពីបញ្ហានេះនឹងធ្វើឡើងនៅថ្ងៃច័ន្ទនាសប្តាហ៍ក្រោយ ។

## ៤. ការគ្រប់គ្រងសវនាការ

### ការគ្រប់គ្រងផ្នែកតុលាការ

***បញ្ហាការសួរដេញដោលជនជាប់ចោទ :*** នាថ្ងៃច័ន្ទ បន្ទាប់ពីអង្គជំនុំជម្រះប្រកាសថា ការសួរដេញដោលសាក្សី **ហ៊ីម ហ៊ុយ** ត្រូវបញ្ចប់ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំអង្គជំនុំជម្រះសួរជនជាប់ចោទ ពីការលែងទុកចិត្តលើកម្មាភិបាល **ហ៊រ** ។ មេធាវីការពារក្តីលោក **Francois Roux** ឆ្លើយតបដោយកត់សម្គាល់ថា ការទទួលបានពេលវេលាបន្ថែមនេះ គឺមិនមានតុល្យភាព

ចំពោះម៉ោងពេលដែលបានកំណត់ឱ្យទៅសហព្រះរាជអាជ្ញានោះទេ ។ គាត់បន្ថែមថា ប្រសិនបើសំណើនេះត្រូវបានអនុញ្ញាត សហមេធាវីការពារក្តី ទាមទាររយៈពេលបន្ថែមដូចគ្នានេះដែរ ។ ប្រធានអង្គជំនុំជម្រះលោក **និល ណុន បាន**ច្រានចោលសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយពុំផ្តល់ហេតុផល ថាតើសំណើនោះមិនមានសារៈសំខាន់ ឬ ផ្ទុយនឹងម៉ោងពេលដែលបានកំណត់ហើយ ។

ម៉ោងកំណត់ក្នុងការដេញដោលជនជាប់ចោទត្រូវពិភាក្សាម្តងទៀត នៅថ្ងៃពុធ នៅពេលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ លោកស្រី **Martine Jacquin** ស្នើសុំអង្គជំនុំជម្រះគួរសម្រេចតាមសំណើសហព្រះរាជអាជ្ញា លើការផ្លាស់ប្តូរពេលសួរដេញដោល ។ ចំណែកលោកស្រី **Silke Studzinsky** បានដាក់ការសន្និដ្ឋានស្នើសុំថា ភាគីគួរអនុញ្ញាតដាក់សំណួរសេសសល់ទៅអង្គជំនុំជម្រះសួរសាក្សី នៅពេលអស់ម៉ោងពេលសួរដេញដោល ។ មេធាវីការពារក្តីលោក **Roux** បានធ្វើការសង្កេតលើសំណើទាំងពីរថា គឺមានគោលបំណងដូចគ្នា សុំបន្ថែមពេលវេលាសួរដេញដោលភាគី ។ លោក **Roux** បានបង្ហាញថា ការបង្កើនល្បឿនកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានសម្រេចលើម៉ោងពេលសួរដេញដោលភាគី ប្រសិនបើផ្តល់ពេលបន្ថែមនាំឱ្យកិច្ចដំណើរការនីតិវិធីឈានត្រឡប់ក្រោយ ។ អង្គជំនុំជម្រះ ប្រកាសថា សេចក្តីសម្រេចនឹងលើកទៅថ្ងៃច័ន្ទ នាសប្តាហ៍ក្រោយ ។

***ឥរិយាបទកើតមាននៅសវនាការ :*** នៅថ្ងៃពុធ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិក្រុម៣ បានប្រើប្រាស់ម៉ោងពេលសួរដេញដោលសាក្សី **ប្រាក់ ខន** ទៅសួរជនជាប់ពីទស្សនៈវិស័យរបស់គាត់លើសាក្សីរូបនេះ ។ **ឌុច** បានចង្អុលបង្ហាញថា សាក្សីរូបនេះ ហាក់មានកំរិតការយល់ដឹងតិចពីមន្ទីរ ស-២១ ការងារអ្នកសួរចម្លើយមិនមែន ជាការងាររបស់គណៈមជ្ឈឹមបក្សកម្មុយនីស្តឡើយ ។ គាត់បន្តថ្លែងរិះគន់លើសក្ខីកម្មដែលគ្មានមូលដ្ឋាន ដោយមិនមានឯកសារគាំទ្រសក្ខីកម្មនោះ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ លើកឡើងថា ការថ្លែងដោយផ្ទាល់ទៅសាក្សី អង្គជំនុំជម្រះបានសម្រេចរួចហើយមិនឱ្យធ្វើបែបនេះទេ ។

***វត្តមានសាធារណៈជន :*** នៅថ្ងៃច័ន្ទ អ្នកចូលរួមសវនាការប្រហែល ៣០០នាក់ មកពីខេត្តកណ្តាល និងប្រជាពលរដ្ឋប្រមាណ ៥០ នាក់ មកពីខេត្តកំពង់ចាម ដែលក្នុងនោះមាន ៣ នាក់ ជាអតីតកូនសិស្ស **ឌុច** នៅទសវត្សន៍ឆ្នាំ១៩៦០ ។ នៅថ្ងៃអង្គារ ផ្នែកកិច្ចការសារធារណៈ នៃ អ.វ.ត.ក. បានរៀបចំប្រជាពលរដ្ឋ ២០០នាក់ មកពីស្រុកកងមាស ខេត្តកំពង់ចាម ។ នៅថ្ងៃពុធ ចំនួនអ្នកចូលរួមកិច្ចនីតិវិធី ប្រហែល ៤០០នាក់ មកពីស្រុកសន្ទុក ខេត្តកំពង់ធំ រួមទាំងព្រះសង្ឃជាច្រើនអង្គ និងមានមនុស្សម្នាក់ដែលគេស្គាល់ថា ជាមិត្តភក្រ្តជិតស្និតរបស់ជនជាប់ចោទ ។

***ការចូលរួមរបស់ភាគី :*** នាសប្តាហ៍នេះ លោក **សេង ប៊ុនខេង** តំណាងសហព្រះរាជអាជ្ញាជាតិ នៅថ្ងៃច័ន្ទ និងលោក **តាន់ សេណារុង** តំណាងនៅថ្ងៃអង្គារ និងថ្ងៃពុធ ។ ចំណែកឯលោក **William Smith** តំណាងសហព្រះរាជអាជ្ញាអន្តរជាតិពេញមួយសប្តាហ៍ ។ នៅថ្ងៃពុធ មេធាវីការពារក្តីអន្តរជាតិលោក **Francios Roux** បានប្រកាសឱ្យដឹងថា គាត់នឹងអវត្តមាននៅសប្តាហ៍ក្រោយ ដោយមេធាវីការពារក្តីជាតិលោក **ការ សាវុធ** នឹងការពារជនជាប់ចោទ ។

***តារាងគ្រប់គ្រប់ពេលវេលា :*** នៅសប្តាហ៍នេះ សវនាការប្រព្រឹត្តទៅតែ ៣ថ្ងៃប៉ុណ្ណោះ ប៉ុន្តែកិច្ចនីតិវិធីដំណើរការយ៉ាងស្វិតស្វាញ

និងគោរពម៉ោងពេលវេលាយ៉ាងជាក់លាក់ ។ ទោះបីជាយ៉ាងណា នៅថ្ងៃអង្គារ អង្គជំនុំជម្រះចាប់ផ្តើមនីតិវិធីយឺត ២០ នាទី ។

គួរកត់សម្គាល់ថា នៅរសៀលថ្ងៃច័ន្ទ អង្គជំនុំជម្រះបានសម្រេចបើកសវនាការអសាធារណៈ ដើម្បីដោះស្រាយ *"បញ្ហាបច្ចេកទេស"* ។

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | សម្រាក អាហារថ្ងៃត្រង់ | សម្រាក ពេលរសៀល | ម៉ោងបញ្ចប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ចន្ទ ២០-០៧-០៩ | ០៩:១០ | ១០:៣៥-១១:០០ | ១២:០៥-១៣:៣០ | - | ១៥:០០ | ៤ ម៉ |
| អង្គារ ២១-០៧-០៩ | ០៩:៣០ | ១០:៤០-១១:០៥ | ១២:០៥-១៣:៤០ | ១៥:០០-១៥:២២ | ១៦:១០ | ៤ ម៉ ៣៨ នាទី |
| ពុធ ២២-០៧-០៩ | ០៩:០៥ | ១០:៤០-១០:៥៥ | ១២:១០- ១៣:៣០ | ១៥:០៥-១៥:២០ | ១៦:០០ | ៥ ម៉ ៥ នាទី |
| ព្រហស្បត្តិ ២៣-០៧-០៩ | - | - | - | - | - | - |

ចំនួនម៉ោងជាមធ្យម : ៤ម៉ ៤៧នាទី

ចំនួនម៉ោងសរុបនាសប្តាហ៍នេះ : ១៣ម៉ ៤៣នាទី

ចំនួនសរុប ម៉ោង ថ្ងៃ និង សប្តាហ៍ នៅសវនាការ : ២០៥ម៉ ២៥នាទី នៃ ៤៨ ថ្ងៃសវនាការ នៃសប្តាហ៍ទី ១៣

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** ("កម្មវិធី") : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សារិន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/_ ។